សម្លេងខ្មែរនៅបរទេស

## ពីសម័យបារាំង មកមេសា៧៥

# ព្រឹត្តិការណ៍សំខាន់ៗដែលជូនដំណើរប្រទេសខ្មែរធ្វើព្យុហយាត្រាទៅរកការប្រល័យពូជសាសន៍

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១៨ វិច្ឆិកា ២០០៤

**១៨៦៤...** នឹមនៃអាណានិគមបារាំងបានសង្កត់មកលើព្រះរាជាណាចក្រខ្មែរនិងរាជានិយមខ្មែរ ។ គួរកត់សំគាល់ថា កាលណាប្រទេសយើងជាខ្ញុំគេ ប្រជារាស្ត្រយើងតែងទទួលរងទុក្ខវេទនា ក្រោមអំណាចសង្កត់សង្កិននៃអាណាព្យាបាលរបស់គេ ។ ប៉ុន្តែគួរកត់សម្គាល់ដែរថា នឹមរបស់អាណានិគមបារាំង មានទម្ងន់ដូចជាមិនធ្ងន់ធ្ងរណាស់ណាពេកទេ អស់ចំនួន៩០ឆ្នាំមកលើប្រជាជាតិយើង ដែលកំពុងត្រូវរងកម្មនៃសង្គ្រាមបំផ្លិចបំផ្លាញខ្លោចផ្សារ ពីប្រទេសជិតខាងពីរដែលខ្លាំងជាងយើង គឺសៀមហើយនិងយួន ។ កាលណោះមហាអំណាចបារាំងមិនមានគោលបំណងប្លន់យកទឹកដីរបស់យើងឡើយ គ្រាន់តែយកប្រទេសយើងដាក់ទៅក្នុងរណាប «ឥទ្ធិពល»របស់គេប៉ុណ្ណោះ ។ ប្រសិនបើយើងធ្វើការប្រៀបធៀបក្នុងការស្រមៃទៅចុះថា «...មានអាណានិគមយួនឬសៀមមកសង្កត់កយើងវិញ ក្នុងរយៈពេល៩០ឆ្នាំដូចគ្នានេះ (១៨៦៤-១៩៥៤) ម្ល៉េះទឹកដីយើង ជាតិខ្មែរយើងប្រហែលជាគ្មាននៅសល់អ្វីឡើយ ក្រៅពីស្រមោលនៃប្រជាជាតិមួយ ដែលធ្លាប់តែមានអតីតកាលដ៏សែនរុងរឿងប៉ុណ្ណោះ ។ ពីព្រោះជាយូរសតវត្សមកហើយ ប្រទេសសៀមហើយនិងយួន ចេះតែសង្វើញទន្ទ្រាន«លេបត្របាក់»ខេត្តខ្មែរមួយម្តងៗ ទាំងសង្ខាង ។ រីឯគោលបំណងចុងចប់នៃប្រទេសទាំងពីរនេះ គឺវាតយកដីខ្មែរឲ្យអស់រលីងសូន្យតែម្តង រហូតដល់ទន្លេមេគង្គ ដែលគេទុកជាព្រំដែន ។ អាណានិគមបារាំង បើទោះជាមានមុខមាត់អាក្រក់យ៉ាងណាក្តី ក៏បានមក«ចាត់ការ»ទាន់ពេលវេលាដែរ គឺមកធ្វើជា«ប្រាំង» ទប់ទល់នឹងការលោភលន់នៃ«តណ្ហាប្រវត្តិសាស្ត្រយួនសៀមនេះ» កុំឲ្យសំរេចគោលបំណងទៅបាន ។ ឧទាហរណ៍យ៉ាងច្បាស់ក្រឡែត គឺគ្រាន់តែបារាំងទន់ដៃភ្លាមកាលណានៅលើឆាកអន្តរជាតិ (ដូចពេលចាញ់សង្គ្រាមចំពោះប្រទេស អាល្លឺម៉ង់និងជប៉ុនក្នុងឆ្នាំ១៩៤០...) ប្រទេសខ្មែរក៏ត្រូវសៀមកាត់យកខេត្តបាត់ដំបងនិងខេត្តសៀមរាប ទៅធ្វើជាខេត្តរបស់ខ្លួនមួយរំពេជ...។ សៀមប្រគល់ខេត្តទាំង ពីរនេះមកខ្មែរយើងវិញ (១៩៤៦) ដោយសារតែការទ័លច្រក ព្រោះហេតុបានធ្វើនយោបាយខុស ក្នុងប្រការបានចូលដៃចូលជើងជាមួយជប៉ុន ដែលចាញ់សង្គ្រាមលោកលើកទី២ ។

ឧទាហរណ៍មួយទៀត គ្រាន់តែបារាំងទន់ដៃច្បាំងចាញ់យៀកមិញនៅឌៀនបៀនហ្វ៊ូ- យួនយៀកមិញក៏ចាប់ផ្តើមរាតត្បាតវាយលុកចូលមកក្នុងខេត្តក្រចេះនឹងស្ទឹងត្រែងយ៉ាងប្រញាប់ប្រញាល់ (ឆ្នាំ១៩៥៤)... ប៉ុន្តែពុំបានសំរេច ដោយសារស្តេចខ្មែរកំពុងមានប្រជាប្រិយភាពផង ដោយសារការគាបសង្កត់នៃពិភពលោកផង ដោយសារទ័ពយៀកមិញនៅទន់ខ្សោយផង (កងទ័ពយួនកុម្មុយនិស្តវាយប្រហារស្រុកខ្មែរម្តងទៀតដោយចំហ បន្ទាប់ពីព្រឹត្តិការណ៍១៨មិនា១៩៧០... នៅទីបំផុតក៏វាតយកស្រុកខ្មែរកាន់កាប់ជាទីបង្កើយនៅក្នុង ឆ្នាំ១៩៧៩) ។

កំហុសរបស់អាណានិគមបារាំង ដែលបានមកកាន់កាប់ប្រទេសខ្មែរជិតមួយសតវត្ស គឺគេពុំបានអនុញ្ញាតឲ្យប្រជាជាតិខ្មែរមានកម្លាំងរឹងប៉ឹងសោះឡើយ ពីព្រោះពួកគេបានជួយតែខាងយួនតែប៉ុណ្ណោះ ទោះខាងផ្លូវរដ្ឋបាលក្តី ទោះខាងផ្លូវសេដ្ឋកិច្ចក្តី (កំហុសអនុញ្ញាតឲ្យយួនត្រួតក្បាលខ្មែរនេះ ក៏បានបន្តរហូតមកដល់អាមេរិកាំងទៀត រហូតដល់រជ្ជកាលរបស់លោកនិចសុន) ។ ជាហេតុបណ្តាលឲ្យខ្មែរដែលទន់ខ្សោយ នៅតែមានលក្ខណៈទន់ខ្សោយជារៀងដរាប របៀបជាមនុស្សពិការ... (ដោយគេបន្តក់តែទឹកសន្សើមឲ្យរស់នៅផ្តិកៗតែប៉ុណ្ណោះ ធ្វើសាលាភូមិន្ទរដ្ឋបាលបានមួយ, សង់សាលារៀនតូចតាចបាន៩-១០, សង់ស្ពាន៩-១០, សាងផ្លូវជាតិ៩-១០) រីឯយួនជាប្រជាជាតិខ្លាំង គេធ្វើឲ្យរឹតតែខ្លាំងសំបើមមែនទែន សំរាប់តែ«ស្រវាក្តោប»យកស្រុកខ្មែរយើងនិងស្រុកលាវ ពេលបារាំងចេញផុតទៅ ។

**ឆ្នាំ១៨៦៤...** ការដាក់ព្រះរាជាណាចក្រខ្មែរក្នុងអំណាចការពាររបស់អាណានិគមបារាំង ក្រោមសំណូមពររបស់ស្តេចខ្មែរ ព្រោះសៀមហើយនិងយួនសង្វើញយកដីខ្មែរខ្លាំងពេក ។

**ថ្ងៃទី១៧ មិថុនា ១៨៨៤...**ការបង្ខំឲ្យព្រះបាទនរោត្តមប្រគល់អំណាចពិតប្រាកដទៅបារាំង ។ ក្នុងរាត្រីនោះ (វេលាម៉ោង១០យប់) បារាំងបានយកកប៉ាល់ចំបាំងមួយមកសំចតនៅមុខវាំងតែម្តង រួចហើយឥស្សរជនបារាំងម្នាក់ លោក Thomson តំណាងរដ្ឋការអាណានិគម ហែរហមដោយទាហានថ្មើរជើងមួយក្រុម បានដើរសំដៅចូលទៅក្នុងវាំង រហូតដល់មាត់ទ្វារដំណេករបស់ស្តេច ។ គេដាស់ស្តេចឲ្យតើនឡើង ព្រមទាំងបង្ខំឲ្យព្រះរាជាចុះហត្ថលេខា «ស៊ីញ៉េ» សន្ធិសញ្ញា(Convention) ដែលយល់ព្រមប្រគល់អំណាចពិតប្រាកដទៅបារាំង ៖ គឺអំណាច រដ្ឋបាល, យោធា, សេដ្ឋកិច្ច, តុលាការ... ចំណែកស្តេចគ្រាន់តែស្ថិតនៅជា«និមិត្តរូប»នៃអំណាចទូទៅតែប៉ុណ្ណោះ គឺឋិតនៅពីលើអំណាចអ្វីៗទាំងអស់ ប៉ុន្តែគ្មានអំណាចអ្វីទាំងអស់ ។ ស្តេចនរោត្តមក៏បានសុខចិត្តចុះហត្ថលេខាលើសន្ធិសញ្ញា «នៃការកាត់ដៃកាត់ជើងខ្លួនឯងប្រគល់ឲ្យគេ»... គឺមកពីទ្រង់ឋិតនៅក្រោមការគំរាមកំហែងនៃចំពុះទុង។ បារាំងបានធ្វើឲ្យស្តេចសង្កេតមើលថា បើព្រះអង្គមិនយល់ព្រម«ឱនក្បាល»ទេ គេនឹងចាប់ព្រះអង្គញាត់ទ្រុងដូចស្វា ហើយដឹកនាំតាមកប៉ាល់ ដែលសំចតនៅមុខវាំងនោះ តំរង់ឆ្ពោះទៅទីដៅមួយ ដែលគេពុំបានប្រាប់ជាមុន ។ ម៉្យាងវិញទៀត បារាំងសំដែងឲ្យដឹងថា រឿងមួយដ៏សំខាន់បំផុត គឺសូមព្រះអង្គកុំព្រួយបារម្ភពីរឿងខ្វះស្តេចសោយរាជ្យស្នង ។ ពីព្រោះបើអត់ពីព្រះបាទនរោត្តមទៅ ក៏វានៅសល់មហាឧបរាជមួយអង្គទៀត (ដែលដើរកាវ៉េការ៉ានៅក្បែរៗនោះ)ហាក់ ដូចជាចង់សួរថា ៖ «អស់លោកត្រូវការរូបខ្ញុំទេ» ហើយដែលពុំមែនជានរណាក្រៅ ពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ ដែលទ្រង់ច្បាស់ជាពុំមែនជាស្តេចរឹងរូសទាល់តែសោះ ៖ ពោលគឺកន្លែងទំនេរ មានអ្នកប្រចាំការរង់ចាំយកស្រេចទៅហើយ ។ ពេលនោះទេដឹង ដែលទំនាស់ក្តៅងំយូរយារឆ្នាំមកហើយ រវាង«ស្តេចបង»និង«ស្តេចប្អូន»ពាក់កណ្តាលក្លាយទៅជាការ«ស្អប់ខ្ពើមស្លាប់រស់» តរហូតមកដល់កូនចៅ ? ( Cristallisation de la haine) ។

ព្រះបាទនរោត្តមក៏ចុះហត្ថលេខាប្រគល់អំណាចឲ្យបារាំង ក៏ប៉ុន្តែ «ស្តេចដែល មានលក្ខណៈគ្រាន់តែជានាមនេះ» នៅមានមុខងារជាមគ្គទ្ទេសនៃសាសនា គឺព្រះពុទ្ធសាសនាទាំងពីរគណៈ «មហានិកាយនិងធម្មយុត្តិ» ដែលមានឥទ្ធិពលដ៏ខ្លាំងក្លា លើ«បេះដូង» លើចិត្តថ្លើមនៃប្រជារាស្ត្រទូទៅ គឺកម្លាំង«ជំនឿ» កម្លាំង«ទ្រឹស្តីនយោបាយ» ឬឧត្តមគតិ, កម្លាំង«មនោគមវិជ្ជា»នៃប្រជាជាតិខ្មែរទាំងមូលនាសម័យនោះ ។ ដូច្នេះ

ហើយបានជាស្តេចនរោត្តមដែលបាត់បង់អំណាចរលីង របៀបជា «អ្នកនយោបាយពិការ» នៅអាចទាក់ទង ហើយនិងបំបះបំបោររាស្ត្រ ប្រឆាំងនឹងបារាំងជាសម្ងាត់ តាមខ្សែរយៈនៃអ្នកតំណាងសាសនា។ ឧទាហរណ៍ការបះបោររបស់អាចារ្យស្វា និងពោធិកំបោរក៏ត្រូវស្តេចបើកដៃពីរាជវាំងទៅដែរ ដែលជាទម្លាប់មួយរបស់ពូជនរោត្តម...រហូតមកដល់ព្រះករុណាព្រះបាទនរោត្តម-សីហនុ ។

**ឆ្នាំ១៩០៤...** មរណភាពរបស់ស្តេចនរោត្តម និងការចាប់ផ្តើមនៃរជ្ជកាលរបស់ព្រះបាទស៊ីសុវត្ថិ (១៩០៤-១៩២៧) ។ តាំងពីពេលនោះមកមានការចុះសំរុងគ្នាជាខ្លាំង រវាងបារាំងអាណានិគមនិងស្តេចខ្មែរ ដែលជាហេតុឲ្យមានការចាប់ផ្តើមនៃការស្អប់ខ្ពើម ពីសំណាក់បញ្ញាជនខ្មែរនិងពួកអ្នកជាតិនិយម ទៅលើមែកធាងស៊ីសុវត្ថិ... ដោយមានការចោទថាពូជស៊ីសុវត្ថិពុំមែនជាអ្នកស្នេហាជាតិដូចពូជនរោត្តមទេ ។

ជាការពិតស្តេចនរោត្តម ច្រើនមានការលំអៀងទៅប្រទេសសៀមពីព្រោះនៅ ពេលដែលព្រះអង្គឡើងគ្រងរាជ្យ (១៨៦០) ទ្រង់បានទទួលលំពែងតាឆាយ (និមិត្តរូបនៃការកាន់កាប់រាជសម្បត្តិខ្មែរ) ពីប្រទេសសៀម ។ មិនត្រឹមតែប៉ុណ្ណោះ មានមន្ត្រីសៀមដែលមានដើមកំណើតជាជាតិម៉ុងហ្គោល បានមកណែនាំព្រះអង្គឲ្យថ្វាយបង្គំទៅទិសខាងលិច (ក្នុងប្រការនាំស្នួយសារអាករទៅថ្វាយព្រះចៅសៀម) ក៏ប៉ុន្តែដោយពួកភ្នាក់ងារបារាំងមិនបានយល់ព្រម កិច្ចការនេះក៏ពុំបានសំរេច ។

ចំណោកព្រះចៅស៊ីសុវត្ថិវិញ ទំនងជាមានម្តាយយួន ដែលជាកូនចៅតពូជរបស់ស្តេចស្រីកូជិនស៊ិន) មានការលំអៀងទៅប្រទេសយួនយ៉ាងខ្លាំង (គួរជ្រាបថា យួនហើយនិងសៀម ជាតំណពូជរបស់ពួកម៉ុងហ្គោលដែលនៅក្នុងពង្សាវតារពិភពលោក គឺជាពួកវាទទឹកដីនិយម ហើយនិងជាពួកប្រល័យពូជសាសន៍) ។ ជាពិសេសនៅពេលដែលព្រះចៅស៊ីសុវត្ថិឡើងគ្រងរាជ្យ នៅក្នុងរូបថតរក្សាជាផ្លូវការ គេឃើញរូបព្រះអង្គម្ចាស់មុនីវង្សឈរនៅខាងស្តាំនៃព្រះរាជបល្ល័ង្ក ចំណែកនៅខាងឆ្វេងវិញ គេឃើញវត្តមានរបស់ស្តេចយួនម្នាក់ ចេះភាសាបារាំងស្ទាត់បន្លំខ្លួនធ្វើជាថីបកគឺសម្តេចចៅហ្វាវាំងជួន ។ រាងគាត់សង្ហារដូចស្តេចម៉ុងហ្គោល ។ ជននេះដើរតួជាអាជ្ញាកណ្តាល រវាងរដ្ឋការអាណានិគមបារាំង ហើយនិងស្តេចខ្មែរ ។ ដូច្នេះទៅ ដោយមានវរជនកំពូលយួនម្នាក់ មកត្រួតត្រាវាំងខ្មែរទៅហើយ ប្រទេសខ្មែរត្រូវមានខួរក្បាលយួនដោយមិនដឹងខ្លួន ។ ដោយសារអំណាចរបស់អាណានិគមបារាំង និងរបស់ឧត្តមមន្ត្រី(ក្បត់)វាំងជួនគេឃើញមានវរមន្ត្រីនិងឧត្តមមន្ត្រីយួនជាច្រើន មកបង្កប់ខ្លួននៅក្នុងវិស័យសំខាន់ៗនៃប្រទេសកម្ពុជា ក្នុងរដ្ឋបាល ក្នុងកងទ័ព ក្នុងឃ្លាំងប្រាក់ក្នុងស្ថាប័ននៃព្រះពុទ្ធសាសនា ។ ទៅថ្ងៃក្រោយទៅ គេឃើញមានចៅហ្វាយខេត្តនិងមេទ័ពខ្មែរ ដែលសុទ្ធសឹងជាជនជាតិយួនបង្កប់ខ្លួន មានឈ្មោះថា ៖ ញ៉ឹក-ជូឡុង, អ៊ិន-តាំ, សុស្តែន-ហ្វែរណង់ដែស, ហ៊ូ-ហាំងស៊ីន, សេក-សំអៀត ។ល។ និង ។ល។ នៅក្នុងសម័យសាធារណរដ្ឋខ្មែរគេបានឃើញសកម្មភាពដ៏សំខាន់បំផុតរបស់មេទ័ពខ្មែរ សុស្តែន-ហ្វែរណង់ដែស គឺការបូកផ្តុំមកនៅត្រឹមរត់ពន្ធស្រាចូលក្រុងភ្នំពេញ, ការបើកបនល្បែងនៅផ្ទះរបស់ខ្លួន និងការដឹកស្បៀងព្រមទាំងអាវុធយុទ្ធភ័ណ្ឌទៅឲ្យខ្មាំងយួននៅចំការកៅស៊ូជប់ ព្រមទាំងដឹកកៅស៊ូត្រឡប់មកវិញយកមកលក់ឲ្យបារាំង។ ដូច្នេះហើយបានជាគេឃើញអ្នកស្មោះត្រង់នឹងជាតិចេះតែស្លាប់ (យុត្តិវង្ស, អៀវ-កើស, សេង-ស៊ុនថៃ) ចំណែកមនុស្សខិលខូចវិញ ចេះតែឡើងបុណ្យសក្តិតាមជើងខោ ។ នៅសម័យសាធារណរដ្ឋ សូម្បីតែជាងប៉ះកង់ក៏បានពាក់សក្តិប្អូនដែរ...

**ឆ្នាំ១៩២២...** កំណើតរបស់ព្រះអង្គម្ចាស់នរោត្តម-សីហនុ ។ ស្តេចទេវរាជចុងក្រោយនៃពូជវង្សវរ្ម័ននៅក្រុងអង្គរ (គ.ស.១២៩៦) មានឈ្មោះថា ព្រះសីហនុរាជ ឬស្តេចពាល... ជាស្តេចដែលបានត្រូវស្លាប់នឹងលំពែងរបស់តាជ័យ ឬតាត្រសក់ផ្អែម ។ ដូច្នេះនៅក្នុងចំណោម ពួកអ្នកប្រាជ្ញ ពួកព្រាហ្មណ៍បុរោហិត ពួកសម្តេចសង្ឃដែលនៅជុំវិញគ្រួសារស្តេចនរោត្តមក៏មានជនជាតិយួនបង្កប់ខ្លួនដែរ ដោយព្រោះគេអាចមើលឃើញគោលបំណងដ៏ខ្មៅងងឹតរបស់ជនជាតិយួន ពោលរៀបចំយ៉ាងណា ឲ្យស្តេចនរោត្តម-សីហនុ (សីហនុរាជ្យទី២) ក្លាយទៅជាស្តេចពាលនិងបង្កើតកល្លិយុគនៅក្នុងប្រទេសខ្លួនឯង រហូតដល់ភ្លើងឆេះកល្បដូចគ្នានឹងសម័យរលត់រលាយនៃក្រុងអង្គរ ក្រោមសីហនុរាជ្យទី១ដែរ ។

អ្នកតំណាងពូជនរោត្តមម្នាក់ ដែលមានប្រាជ្ញាឈ្លាសវៃ ទ្រង់នរោត្តម-យុគន្ធរ (ជីតាខាងឪពុករបស់នរោត្តម-សីហនុ) បានទៅតវ៉ាចំពោះអំពើអយុត្តិធម៌នៃអាណានិគមបារាំង រហូតដល់រដ្ឋធានីបារាំងតែម្តងគឺក្រុងបារីស ។ ទ្រង់មិនត្រឹមតែមិនបានឡើងសោយរាជ្យប៉ុណ្ណោះទេ ព្រះអង្គថែមទាំងត្រូវបារាំងនិរទេសចោលឲ្យ ទៅស្លាប់នៅស្រុកសៀមថែមទៀតផង ។ ថ្ងៃក្រោយមក មនោសញ្ចេតនាស្នេហាជាតិនៃពួកអ្នកចេះដឹងខ្មែរក៏បានចងភ្ជាប់យ៉ាងជិតស្និទ្ធបំផុត ជាមួយនឹង«មែកធាងនរោត្តម» ។ ឧទាហរណ៍ការជិតស្និទ្ធនៃក្រុមតស៊ូប្រឆាំងបារាំង មានលោកសឺង-ង៉ុកថាន់, ប៉ាជ-ឈឺន, ស៊ឹម-វ៉ារ, ព្រះគ្រូអាចារ្យហែម-ចៀវ ជាមួយនិងព្រះអង្គម្ចាស់នរោត្តម-សុរាម្រិតនិងភរិយារបស់ទ្រង់ ព្រះម្ចាស់ក្សត្រី(ស៊ីសុវត្ថិ) កុសុមៈ-នារីរ័ត្ន (ព្រះបិតានិងមាតារបស់ព្រះអង្គម្ចាស់«ម៉ាប់») ជាហេតុញុំាងឲ្យព្រះអង្គម្ចាស់អធិបតីស៊ីសុវត្ថិ-មុនីរេត ត្រូវរបូតរាជសម្បត្តិ និងឲ្យមានរជ្ជកាលនៃព្រះបាទនរោត្តម-សីហនុវរ្ម័ន ។

**ឆ្នាំ១៩៦៧...** លោកស៊ឹម-វ៉ារបាននិយាយប្រាប់ខ្ញុំថា ៖ «សម្តេចសីហនុចំជាអយុត្តិធម៌ខ្លាំងណាស់...លោកចេះតែចោទអ៊ុំថា ជាពួកសឺង-ង៉ុកថាន់ ដើម្បីយកអ៊ុំទៅសម្លាប់ ។ ក៏ប៉ុន្តែឪពុកម្តាយរបស់សម្តេចសីហនុក៏ជាពួកសឺង-ង៉ុកថាន់ដែរ ។ កាលសម័យបារាំង លោកសឺង-ង៉ុកថាន់, លោកប៉ាជ-ឈឺន ហើយនិងអ៊ុំ ទៅប្រជុំ បាយទឹកនៅផ្ទះមហាក្សត្រីយានីរៀងរាល់អាទិត្យ ដើម្បីរកមធ្យោបាយទប់ទល់នឹងបារាំង ។ ជួនពេលខ្លះសម្តេចសីហនុដែលនៅជាកូនក្មេង ចេញមកខ្លួនទទេ កាន់ខ្លុយមួយមកផង ហើយត្រូវមហាក្សត្រីយានីដេញឲ្យចូលទៅក្នុងវិញ» ។

**ឆ្នាំ១៩២៧...** មរណភាពរបស់ព្រះករុណាព្រះបាទស៊ីវត្ថិ និងការចាប់ផ្តើមរជ្ជកាលរបស់ព្រះបាទស៊ីសុវត្ថិ-មុនីវង្ស ។ ចៅហ្វាវាំងជួន បានប្រើមធ្យោបាយឲ្យស្តេចអង្គនេះ ទៅជាឆ្កួតឡប់សតិ ដោយបុព្វហេតុសេចក្តីទោមនស្សល្វីងជូរចត់នឹងរដ្ឋការបារាំង ដែលជួយស្នួយតែជនជាតិយួន ហើយបន្តុះបង្អាប់តែជនជាតិខ្មែរ ។ មន្ត្រី(យួនបង្កប់ខ្លួន)ជាច្រើននាក់ធ្វើឲ្យស្តេចឆ្កួតនឹងតណ្ហា ដោយយកប្រពន្ធខ្លួនឯងទៅថ្វាយស្តេច តាមពិតច្រើនតែជាស្រីពេស្យាយួន រួចហើយស្តេចក៏ចែកដីធ្លី ទៅឲ្យស្រីយួននោះ ដែលឡើងចាងជាងចៅហ្វាយស្រុកទៅទៀត ។ មន្ត្រីយួនក្នុងវាំងបានណែនាំឲ្យស្តេចទាស់ជាមួយព្រះសង្ឃ ហើយទ្រង់ដើរជេរប៉ាតណាប៉ាណី ហើយនិងខោកក្បាលព្រះសង្ឃតាមផ្សារផ្សេរ រួចហើយពួកគេនាំគ្នាហៅស្តេចថា «អាចំកួតហ្លួង» ។

**ឆ្នាំ១៩៤០...** បារាំងធ្វើសង្គ្រាមចាញ់អាល្លឺម៉ង់ណាស៊ីអ៊ីត្លែរនិយម ចំណែក ប្រទេសកម្ពុជាធ្លាក់ក្រោមឥទ្ធិពលនៃជប៉ុនហ្វាស៊ីសយោធានិយម ។ សៀមដែលធ្វើបក្សសម្ព័ន្ធជាមួយនឹងជប៉ុន ក៏បានកាត់ខេត្តខ្មែរពីរបាត់ដំបងនិងសៀមរាប ទៅធ្វើជាខេត្តរបស់ខ្លួន ។ ជាដើមហេតុឲ្យព្រះករុណាព្រះបាទស៊ីសុវត្ថិ-មុនីវង្សប្រឈួនយ៉ាងធ្ងន់ រត់ទៅពួនសម្ងំនៅព្រះរាជដំណាក់ភ្នំបូកគោរហូតដល់ស្លាប់ ។

ប៉ុន្តែតាមប្រភពច្បាស់ការណ៍ (ព្រះរាជបំរើសម័យហ្លួងមុនីវង្សម្នាក់បាននិយាយរឿងរ៉ាវទាំងអស់នោះប្រាប់ខ្ញុំ) ហ្លួងមុនិវង្សបានចូលមរណ

ភាព ដោយសារយួនធ្វើឃាត ។ កាលសម័យនោះ ហ្លួងចូលចិត្តបើកឡានផ្លិត (ស៊ីត្រូអែនខ្មៅ) ធ្វើដំណើរតែម្នាក់ឯង ទៅជក់កញ្ឆា នៅផ្ទះអ្នកស្រុកម្នាក់នៅខេត្តកំពត ។ ព្រឹកថ្ងៃមួយ ស្រាប់តែគេរកឃើញខ្មោចព្រះកូណានៅផ្ទះអ្នកស្រុកខាងលើនេះ ។ ដើម្បីចៀសវាងពាក្យនិន្ទា គេក៏បិទបាំងរឿងអាស្រូវទាំងប៉ុន្មាន ហើយក៏ដឹកខ្មោចព្រះកូណាទៅដឹកលល់នៅភ្នំបូកគោ ។ ដូច្នេះយួនបានបំពុលហ្លួងមុនីវង្ស (គឺដោយហេតុថា រឿងអ្វីៗក៏វាមិនកំបាំងភ្នែកវាំងជួនដែរ) ព្រោះពេលវេលាបានមកដល់ហើយ ដើម្បីឲ្យស្ដេចពាល«សីហនុ» ឡើងគ្រងរាជ្យស្វែងទៅរកសភាពអណ្ដូរក័ប្ប ។

**ឆ្នាំ១៩៤១...** ព្រះបាទស៊ីសុវត្ថិ-មុនីវង្សចូលទីវង្គត់ ។ ការចាប់ផ្ដើមរជ្ជកាលនៃព្រះករុណានរោត្ដម-សីហនុ ក្នុងអសន្តិសុខដោយបារាំងទន់ដៃ ព្រមទាំងមានការរាតត្បាតពីមហាអំណាចអាស៊ីជំនាន់ថ្មី គឺពួកហ្វាស៊ីសជប៉ុន ។

គួរកត់សំគាល់ថា ពេលស្ដេចសីហនុឡើងគ្រងរាជ្យ ព្រះរាជបំរើ (យួនបង្កប់ខ្លួន) មានការ<ធ្វេសប្រហែស>ភ្លេចបិទបង្អួច ជាហេតុបណ្ដាលឲ្យមានខ្យល់ចូល ធ្វើឲ្យរលត់ភ្លើងទៀនជ័យ ដែលគេតម្រូវឲ្យឆេះចំនួនបីយប់បីថ្ងៃ ។ ម្ចាស់ក្សត្រីកុសុមៈ ម្ដាយរបស់សម្ដេចសីហនុ មានការភ័យតក់ស្លុតតក្កមា ពីព្រោះបើកាលណាភ្លើងទៀននេះរលត់មុនថ្ងៃកំណត់តាមជំនឿដុះស្លែក្នុងព្រះរាជវាំង (ដែលយួនជាអ្នកបង្កើត) ក្នុងរាជ្យស្ដេចអង្គនេះ នឹងមានកើតកលិយុគដ៏មហាកាចសាហាវ ដែលនឹងបណ្ដាលឲ្យប្រជារាស្ត្ររងទុក្ខវេទនា ស្លាប់ព្រាត់ប្រាស់ឈាមហូរដាបពោះដីរ ។

**ឆ្នាំ១៩៤២...** ក្រុមអ្នកជាតិនិយម (មានជាពិសេសគឺក្រុមព្រះសង្ឃបដិវត្តន៍ ក្រោមការដឹកនាំនៃព្រះគ្រូអាចារ្យហែម-ចៀវ ដែលមានអ្នកនយោបាយសឺង-ង៉ុក ថាន់និងប៉ាជ-ឈឺននៅពីក្រោយខ្នង) ធ្វើបាតុកម្មបះបោរប្រឆាំងនឹងបារាំងដោយបានវាយអ្នកតំណាងជាន់ខ្ពស់ **Résident supérieur** នឹងឆ័ត្រព្រះសង្ឃបែកក្បាលចេញឈាម ។ កិត្យានុភាពរបស់បារាំងធ្លាក់ខ្សោយដល់បាតដាល ។

បើយើងរត់លឿនស្លេវទៅមុខប្រឆាំងនឹងពន្លឺថ្ងៃ យើងមិនអាចមើលឃើញស្រមោលខ្លួនឯង ឬស្រមោលនៃសេចក្ដីពិតនោះបានឡើយ ។ ក៏ប៉ុន្តែបើយើងមើលត្រឡប់ថយក្រោយវិញ ជួនកាលយើងនឹងអាចក្រឡេកឃើញស្រមោលនៃព្រាយបិសាចតែម្ដង ។ តាមពិតបាតុកម្មបះបោរប្រឆាំងនឹងបារាំងនេះ ពុំមែនជាលក្ខណៈនៃសេចក្ដីស្នេហាជាតិនោះទេ តែជាកំហុសនយោបាយមួយដ៏ធ្ងន់ធ្ងរ ។ តាមពិតអ្នកនយោបាយស្នេហាជាតិរបស់យើង ព្រមទាំងព្រះសង្ឃរបស់យើង បានធ្លាក់ក្នុងកលឧបាយរបស់យួន ពីព្រោះថាកាលសម័យនោះ បារាំងអាណានិគមដើរតួ ជាអាជ្ញាកណ្ដាលរវាងខ្មែរយើងហើយនិងយួនអណ្ណាម ។ បើព្រះសង្ឃខ្មែរវាយអាជ្ញាជាន់ខ្ពស់បារាំងឲ្យបែកក្បាលទៅហើយ តើធ្វើម្ដេចនឹងបារាំងប្រគល់ទឹកដីកម្ពុជាក្រោមមកឲ្យយើងវិញ ? ។ ក្នុងប្រការនេះ យួនវាប្រើខ្មែរឲ្យដាំបាយ លុះដល់បាយឆ្អិន វាចាំតែលោតចូលស៊ីតែម្ដង ។ កាលសម័យនោះ បើឧបមាជប៉ុនឈ្នះបារាំង ជប៉ុននឹងកាត់ទឹកដីខ្មែរ បាត់ដំបងនិងសៀមរាប ទៅឲ្យសៀមជាស្ថាពរ ។ ក៏ប៉ុន្តែបើបារាំងឈ្នះជប៉ុនវិញ យើងនឹងត្រូវបាត់បង់ទឹកដីខាងកើត ដោយសារតែកំហុសព្រះសង្ឃដែលធ្វើនយោបាយ ។

**ថ្ងៃ៩ មិនា ១៩៤៥...** រដ្ឋប្រហាររបស់លោកសឺង-ង៉ុកថាន់ដណ្ដើមអំណាចពីបារាំង ដោយតែងតាំងខ្លួនលោកជារដ្ឋមន្ត្រីទី១ យោងតាមព្រះរាជក្រមតែងតាំងពីព្រះករុណា ។ សមាសភាពដ៏ចម្លែកនៃរដ្ឋាភិបាលរបស់លោកសឺង-ង៉ុកថាន់នៃ ថ្ងៃទី១៤ សីហា ១៩៤៥ គឺ ៖

សឺង-ង៉ុកថាន់ ៖ រដ្ឋមន្ត្រីទី១ និងរដ្ឋមន្ត្រីក្រសួងការបរទេស

នរោត្តម-ម៉ុងតាណា ៖ កសិកម្ម, ស៊ុម-ហៀង ក្រសួងមហាផ្ទៃ, វ៉ាំរ-កាមែល ក្រសួងធម្មការ, ប៉ាជ-ឈឺន ក្រសួងផ្គត់ផ្គង់សម្ភារៈ, ពីទូ-ដឺម៉ុងតេរ៉ូ ក្រសួងយុត្តិធម៌, ឃឹម-ទិត ក្រសួងការពារជាតិ សុខាភិបាល សាធារណការ, ញឹក-ជូឡុង សេដ្ឋកិច្ចជាតិ, ប៉ែន-នុត ក្រសួងហិរញ្ញវត្ថុ ។ ការដែលគួរឲ្យព្រឺក្បាលបំផុត គឺមានកុងស៊ីយួនបង្កប់ខ្លួនយ៉ាងតិចក៏៥នាក់ (វ៉ាំរ-កាមែល, ឃឹម-ទិត, ញឹក-ជូឡុង, ពីទូ-ដឺម៉ុង តេរ៉ូ, ប៉ាជ-ឈឺន) ដែលណែនាំលោកសឺង-ង៉ុកថាន់ឲ្យប្រឆាំងបារាំង រួចហើយទៅណែនាំបារាំងឲ្យមកចាប់លោកសឺង-ង៉ុកថាន់វិញ ។ ជនទាំងនេះ គឺសុទ្ធសឹងតែជាពួកភ្នាក់ងារបារាំងទេតើ ! ។

**ឆ្នាំ១៩៤៦...** កំណើតនៃរបបរាជាសភានិយម ។ គឺជាឆ្នាំនៃការបង្កើតគណបក្សនយោបាយជាលើកដំបូងបំផុត គឺឆ្នាំកំណើតនៃសម្បជញ្ញៈជាតិ និងជោគជ័យនៃគណបក្សប្រជាធិបតេយ្យ ទៅលើព្រះរាជា និងទៅលើបារាំងអាណានិគម ។

**ឆ្នាំ១៩៤៧...** ឆ្នាំនៃកិត្យានុភាពកំពូលរបស់គណបក្សប្រជាធិបតេយ្យ ដែលបានតុបតែងរដ្ឋធម្មនុញ្ញ ក្រោមការដឹកនាំរបស់ទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស (**Docteur Es-Sciences**) ។ ជាឆ្នាំដ៏ល្បីរបស់ស្ដេចបញ្ញវ័ន្តអាយុខ្លីនេះ ព្រមជាឆ្នាំចប់ផង (ពីព្រោះទ្រង់កើតរបេង)...

តាមពិតទ្រង់យុត្តិវង្ស បានត្រូវលោកយែម-សំបូរ (ទ្រឿង-មិញយ៉ាងបង្កប់ខ្លួន) ដែលជាលេខាធិការពិសេស (**S.P.**) របស់ទ្រង់ដាក់ថ្នាំបំពុលឲ្យស្លាប់ ។ ក៏ប៉ុន្តែ យួនបានធ្វើប្រជារាស្ត្រខ្មែរមើលឃើញថា ជាបារាំងទៅវិញ ដែលជាអ្នកពិឃាតស្ដេចចេះដឹង (យុត្តិវង្ស) ហើយលើកស្ដេចបន្ទុបល្ងង់ខ្លៅឲ្យឡើងបុណ្យជារៀងដរាប ។ នៅក្នុងពេលជាមួយគ្នានោះ យួនក៏ធ្វើឲ្យភ្នែកបារាំងមើលមកខ្មែរឃើញជាសាសន៍ល្ងង់ខ្លៅ ល្មមតែបាត់បង់ទឹកដីរបស់ដូនតា ឲ្យឃើញថាការវាតទឹកដីខ្មែរពីសំណាក់យួនអណ្ណាម គឺជាគោលបំណងរបស់ព្រះជាម្ចាស់ ។

**ឆ្នាំ១៩៤៩...** ការចោលគ្រាប់បែកពិឃាតលោកអៀវ-កើស ប្រធាននៃគណបក្សប្រជាធិបតេយ្យ ពីសំណាក់មេប៉ូលិស មានឈ្មោះថា សេង-ទិព្វ (ដែលមានឯកឧត្តមយ៉ែម-សំបួរ ជានាយករដ្ឋមន្ត្រី អតីតសមាជិកនៃគណបក្សប្រជាធិបតេយ្យម្នាក់ ជាអ្នកបង្គាប់បញ្ជា) ។ គួរជ្រាបថា លោកយ៉ែម-សំបួរនេះ បានធ្វើរដ្ឋប្រហារប្រឆាំងនឹងគណបក្សប្រជាធិបតេយ្យ ហើយបានបង្កើតរដ្ឋាភិបាលផ្ដាច់ការមួយប្រឆួបារាំង ។ កាលណោះ ក្រុមនិស្សិតខ្មែរបានបង្កើតពាក្យស្លោកថា ៖ «មាស-សាឯម, យ៉ែម-សំបួរ... បើកកាស៊ីណូបិទវិទ្យាល័យ... ហ៊ុយ-ម៉ោងៗ » ។ តាំងពីថ្ងៃនោះមក គណបក្សប្រជាធិបតេយ្យស្រុតចុះរហូត ចំណែកព្រះករុណានរោត្តម-សីហនុក៏ឡើងប្រជាប្រិយភាព រហូតដល់ជាកំពូលវិរបុរសទល់ថ្ងៃ១៨មិនា១៩៧០ ។

តាមពិតគេសម្លាប់លោកអៀវ-កើស ពីព្រោះលោកប្រធានរដ្ឋសភានេះ មិនព្រមចុះហត្ថលេខាលើលក្ខន្តិកៈនៃផែនទីឥណ្ឌូចិនថ្មី ដែលកាត់កម្ពុជាក្រោមទៅឲ្យយួន ។ គេធ្វើឲ្យព្រះកូណាសីហនុឡើងប្រជាប្រិយភាព ក៏ដើម្បីឲ្យទ្រង់ស៊ីញេទៅលើលក្ខន្តិកៈថ្មីរបស់បារាំងនេះ ជំនួសលោកអៀវ-កើស ។ ព្រះករុណាជាស្ដេចពាលល្ងង់ខ្លៅពិតមែន ជាស្ដេចឈ្លក់វង្វេងនឹងកាមតណ្ហា ក៏ប៉ុន្តែព្រះអង្គត្រូវអមដោយគ្រូពីរនាក់ ដែលសុទ្ធតែជាអ្នកចេះដឹង គឺលោកហ៊ុយ-គន្ធុល ហើយនិងលោកសឺន-សាន ។ គ្រូទាំងពីរនាក់មិនបានឃាត់ដៃព្រះកូណាទេ បែរជាជំរុញថែម ឲ្យព្រះកូណាស៊ីញេចែកទឹកដីឲ្យទៅយួន ។ បន្ទាប់មក គេក៏បានឃើញតុរង្វាន់ដ៏ចម្លែក គឺលោកហ៊ុយ-គន្ធុលបានឡើងបុណ្យ ជានាយករដ្ឋាភិបាល ចំណែកលោក សឺន-សាន បានឡើងបុណ្យជាប្រធានរដ្ឋសភានៃគណគណបក្សប្រជាធិបតេយ្យ ។

**ឆ្នាំ១៩៥០...** យួនយៀកមិញម្នាក់បានពិឃាតអ្នកតំណាងជាន់ខ្ពស់នៃវដ្ដការបារាំង គឺលោក Jean De Raymond នៅវិមានរដ្ឋាភិបាល ។ ក៏ប៉ុន្ដែក្នុងឯកសារជា ផ្លូវការគេដាក់ថា គឺកូនចៅលោកសឺង-ង៉ុកថាន់ជាឃាតករ ។ ដូច្នេះ គេចង់ធ្វើឲ្យឃើញថា បារាំងហើយនិងខ្មែរមើលមុខគ្នាមិនត្រង់ ។ នៅគ្រប់ប្រការ យួនជាអ្នកចាំទទួលភោគផល ។

**ឆ្នាំ១៩៥៤...** ព្រះកូណានរោត្ដម-សីហនុបានទទួលឯករាជ្យពេញលេញពីបារាំងពិតមែន ប៉ុន្ដែគឺជាឯករាជ្យដែលបាត់បង់ទឹកដីកម្ពុជាក្រោម ។

**ឆ្នាំ១៩៥៥...** ព្រះកូណានរោត្ដម-សីហនុដាក់រាជ្យថ្វាយព្រះវរបិតាក្នុងគោលបំណងចុះមកធ្វើនយោបាយផ្ទាល់ ក្នុងសៃរៀនប្រជារាស្ដ្រ ជាមេគណបក្សតែ១របស់ខ្មែរ «សង្គមរាស្ដ្រនិយម» ជាអ្នកកាន់អំណាចពិតប្រាកដ ជាមហាបុរសជាតិ ជាព្រះអគ្គមគ្គទ្ទេសក៍ ។

**ឆ្នាំ១៩៥៨...** ព្រឹត្តិការណ៍នៃការក្បត់ចំពោះនយោបាយអព្យាក្រឹត្យនិយមរបស់សម្ដេចសីហនុ ពីសំណាក់វរជន សម-សារី និងឧត្ដមសេនិយឈួន-ម្ជូលពេជ្រ ហៅដាបឈួន ដោយមានសេអ៊ីអាអាមេរិកាំងនៅក្រោយខ្នង ជាហេតុឲ្យសម្ដេចលែងទុកចិត្តអាមេរិកាំងអស់រលីង ហើយ «ដកឃ្លា»ពីមហាប្រទេសសេរីនិយមនេះបន្ដិចម្ដងៗ ។ នៅក្នុងក្របខ័ណ្ឌនៃអំពើក្បត់នេះ សម្ដេចសីហនុបានបញ្ជាឲ្យពិឃាតបញ្ញាជនជាច្រើនដែលច្រើនតែជាអ្នកស្មោះត្រង់នឹងមហាក្សត្រីកុសុមៈ មានជាអាទិ៍មេយុវ័ន ស៊ីសាមុត-សុវណ្ណារី ...

**ឆ្នាំ១៩៦០...** ព្រះករុណាសុរាម្រិតចូលទីវង្គត់ ។ សម្ដេចសីហនុទុករាជបល្ល័ង្កឲ្យនៅទំនេរ ប្រគល់ឲ្យម្ដាយក៏មិនព្រមប្រគល់ឲ្យពិតប្រាកដចំណែកខ្លួនលោក តែងតាំងខ្លួនឯងជាប្រមុខរដ្ឋ ។ ធម្មតាស្ដេចគឺជាប្រមុខរដ្ឋទៅហើយ ប៉ុន្ដែបើប្រទេសណាមានស្ដេចផង មានប្រមុខរដ្ឋផង (ដូចប្រទេសខ្មែរក្នុងឆ្នាំ៦០) គឺប្រទេសដែលមានស្ដេចពីរ គឺជាប្រភពនៃទំនាស់អណ្ដូរកប្ប ពីព្រោះប្រទេសដូច្នេះពុំអាចមា នស្ថេរភាពនយោបាយកើតឡើយ ។

**ឆ្នាំ១៩៦៤...** ព្រឹត្តិការណ៍នៃការសំរេចធ្ងន់ធ្ងររបស់សម្ដេច លែងទទួលជំនួយសេដ្ឋកិច្ចអាមេរិកាំង ដែលជាហេតុជំរុញឲ្យស្រុកខ្មែរធ្លាក់ចូលក្នុងអន្ទាក់កុម្មុយនិស្ដយៀកកុង ដោយគ្មានថ្ងៃរើបំរះរួច ។

**ឆ្នាំ១៩៧០...** ឆ្នាំនៃប្រទេសខ្មែរ«ស្លរឈាម»ដាច់ខ្យល់ ដោយស្ដេចអាទិទេពមួយល្បីឈ្មោះដូចទេវតា ទាំងក្នុងប្រទេស ទាំងលើឆាកអន្ដរជាតិ ដួលរលំត្មោល «ដូចគោដឹកសៀង» ដោយគ្មាននរណារុញច្រាន ។ «ពួកម៉ាក»របស់លោកនេរុ លោកស៊ូការណូ, លោកជូ-អេនឡាយ, លោកដឹហ្គោល, លោកទីតូ មកចាញ់ប្រៀប «ឯកឧត្ដមឧត្ដមសេនិយលន់-នល់» អតីតស័ក្ដិ៥នៅខេត្តបាត់ដំបង (ពេលបេសកកម្មសាមគ្គីនៃព្រះកូណាសីហនុ) ដែលជាមេទាហានម្នាក់រាងស្លូយ ប្រាជ្ញាស្លក់ ដែលគ្មានតណ្ហាលោភលន់អ្វីក្រៅពីបំរើស្ដេចតែប៉ុណ្ណោះឯង (!!)

ក្រោយថ្ងៃ១៨មិនា ប្រសិនបើសម្ដេចសីហនុមិនបានរត់ចូលទៅបំរើយៀកកុងទេ ហើយមិនបានពន្យុះទាហានយួន ឲ្យមកវាយប្រហារស្រុកខ្មែរទេ «ឯកឧត្ដមឧត្ដមសេនិយ»នេះ ប្រហែលជាកាន់អំណាចមិនបានបាន៦ខែផងទេដឹង ? គឺសង្គ្រាមបំផ្លិចបំផ្លាញស្រុកខ្មែរ ពីសំណាក់យួនខាងជើងទេតើ ដែលចិញ្ចឹមអំណាចរបស់ លោកប្រធានាធិបតីលន់-នល់ បានរហូតដល់៥ឆ្នាំ...

**មេសា ៧៥...** ខែវេងកម្ម ឆ្នាំព្រាត់ប្រាស់។ គឺជារជ្ជកាលរបស់ប៉ុលពតដែល ចាប់ផ្ដើមឡើង... ឆ្នាំនៃសេចក្ដីស្លាប់របស់ដួងព្រលឹងនៃប្រជាជាតិខ្មែរទាំងមូល ។

**សេចក្ដីបញ្ចប់** ៖ ព្រឹត្តិការណ៍ទាំងអស់ខាងលើនេះ ពុំមែនជាចំណារនៃព្រហ្មលិខិតទេ គឺជាចំណាររបស់ជនជាតិយួន (!!) ។៚

❑